**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០១...សសរ.....

**សេចក្តីសម្រេច**

**ស្តីពីការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី**

**អភិវឌ្ឍន៍ជនបទ និងលុបបំបាត់ភាពក្រីក្រអាស៊ាន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**ប្រការ១ :** បង្កើតគណៈកម្មការមួយដើម្បីរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទ និងលុបបំបាត់ភាពក្រីក្រអាស៊ាន លើកទី៣ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **លី ធុជ** | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាប្រធាន |
| ២-ឯកឧត្តម **ហ៊ុយ កន្ធុល ធរ៉ា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាអនុប្រធាន |
| ៣-ឯកឧត្តម **យឹម វៃលី** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាអនុប្រធាន |
| ៤-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥-ឯកឧត្តម **ទី ចំឡេងផល** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៦-ឯកឧត្តម **សួស គង់** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៧-ឯកឧត្តម **ឡាយ អ៊ីពីសិទ្ធិ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៨-ឯកឧត្តម **សេ៎ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ៩-ឯកឧត្តម **ម៉ុច សុខិន** | អភិបាលរងទី៣ខេត្តសៀមរាប | ជាសមាជិក |
| ១០-ឯកឧត្តម ឧ.ឯក **សូ ផន** | អគ្គនាយករងទី១នគរបាលជាតិ | ជាសមាជិក |
| ១១-លោក **នុយ រី** | អគ្គនាយករង អគ្គលេខាធិការជាតិអាស៊ាន | |

| | | |
|---|---|---|
| | ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ១២-លោក **វិះចក សុខារី** | អគ្គនាយករង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ជាសមាជិក |
| ១៣-លោក វ.ឯក **ណឹម សុផា** | នាយករងសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសមាជិក |
| ១៤-លោក **សៅ ជីវ័ន្ត** | ប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទ | ជាលេខាធិការ |
| ១៥-លោក **សៅ ស៊ីសុវណ្ណា** | អនុប្រធាននាយកដ្ឋានអាស៊ានទីស្ដីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ១៦-លោក **នួត សារ៉ាវុធ** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |

**ប្រការ២ :** គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារៈកិច្ចដូចតទៅ :

ក-រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប ។

ខ-រៀបចំគំរោងថវិកាសំរាប់ចំណាយក្នុងកិច្ចប្រជុំនេះដើម្បីលើកសំណើសុំពីរាជរដ្ឋាភិបាល ។

គ-សំរបសំរួល រៀបចំការពារសន្តិសុខជូនដល់គណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាពល្អ ។

ឃ-ជួយសំរបសំរួល និងចាត់ចែងលើការធ្វើដំណើរទស្សនាចរជូនគណៈប្រតិភូក្រោយកិច្ចប្រជុំចប់ យោងតាមកម្មវិធីដែលបានគ្រោងទុក ។

ង-ជួយសំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិដើម្បីធ្វើការផ្សព្វផ្សាយកិច្ចប្រជុំនេះ ។

**ប្រការ៣ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង និងស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំពិភាក្សា និងដោះស្រាយការងារតាមការចាំបាច់ ។

**ប្រការ៤ :** គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗតាមការចាំបាច់ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ៥

-ឯកសារ-កាលប្បវត្តិ